**ការបញ្ចេញនូវព័ត៌មានក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌប្រទេសបារាំង (disclosure of information) (Brando Matteo Fiori, Disclosure of Information in Criminal Proceedings: A Comparative Analysis of National and International Criminal Procedural Systems and Human Rights, 2015, pp. 85-114)**

**១.** ក្នុងដំណើរការក្តីព្រហ្មទណ្ឌ ព័ត៌មានដែលជាភស្តុតាង ក្នុងន័យទូលាយ មានសារៈសំខាន់ណាស់ ដើម្បីជួយភាគីក្នុងការការពារប្រយោជន៍ឬសិទ្ធិ។ ជាការអនុវត្ត សិទ្ធិទទួលបានព័ត៌មានឬទាមទារឱ្យផ្តល់ព័ត៌មាន មិនមែនជាការងារងាយស្រួលទេ ដោយសារ វាតម្រូវឱ្យមានក្របខ័ណ្ឌច្បាប់គាំទ្រ ឆន្ទៈ និងយន្តការអនុវត្ត។

**២.** ប្រទេសបារាំង ជាប្រទេសដឹកមុខប្រព័ន្ធច្បាប់ស៊ីវិលឡ ប្រើប្រាស់ប្រព័ន្ធស៊ើបសួរ (inquisitorial system) ជាចម្បងក្នុងដំណើរការក្តីព្រហ្មទណ្ឌ។ ក្នុងច្បាប់ព្រហ្មទណ្ឌឬនីតិវិធីព្រហ្មទណ្ឌ មានបទប្បញ្ញត្តិដោយប្រយោល ចែងតម្រូវឱ្យបញ្ចេញព័ត៌មាន មានក្នុងបទបញ្ជាព្រហ្មទណ្ឌ (criminal ordinance) ដំបូងក្នុងឆ្នាំ១៦៧០ មកដល់ច្បាប់លេខ៥៣៥ ឆ្នាំ២០១៥ នាពេលថ្មីៗនេះ។

**៣.** ការបញ្ចេញព័ត៌មាននេះ សំដៅការបញ្ចេញព័ត៌មានដោយអាជ្ញាធរស៊ើបអង្កេត ដល់ជនសង្ស័យ។ នេះជាការឆ្លើយតបនឹងឬពាក់ព័ន្ធនឹងសិទ្ធិចំនួនបីជាសំខាន់ក្នុងក្របខ័ណ្ឌនៃសិទ្ធិទទួលបានការជំនុំជម្រះសេចក្តីប្រកបដោយយុត្តិធម៌÷ សិទ្ធិត្រូវបានជូនដំណឹងពីបទចោទ សិទ្ធិចូលមើល (ទទួលបាន) ឯកសារសំណុំរឿង (access to dossier) និងសិទ្ធិទទួលបានជំនួយពីមេធាវី ដែលសិទ្ធិចុងក្រោយនេះមានសារៈសំខាន់ ដោយសារមេធាវី ជាអ្នកប្រាប់អំពីសិទ្ធិមួយចំនួនទៅកាន់ជនសង្ស័យ។ កង្វះការទទួលបានឯកសារ និងព័ត៌មានតិចតួច ដែលត្រូវបានបញ្ចេញស្តីពីប្រភេទនៃបទល្មើស រារាំងមេធាវីពីការបង្កើតយុទ្ធ

សាស្ត្រការពារ ចាប់តាំងពីការជួបកូនក្តីរបស់គាត់លើកដំបូង។ មេធាវីត្រូវផ្អែកលើព័ត៌មានផ្តល់ដោយជនសង្ស័យ ដោយគ្មានដឹងអំពីភស្តុតាងប្រមូលដោយនគរបាល។[1]

៤. ក្នុងដំណើរការក្តីព្រហ្មទណ្ឌមកដល់ពេលនេះ មានបញ្ហាប្រឈមក្នុងនីតិវិធីជាច្រើន ដែលត្រូវបានរកឃើញដោយតុលាការជាន់ខ្ពស់របស់ប្រទេសបារាំងខ្លួនឯងថា ខុសនឹងច្បាប់រដ្ឋធម្មនុញ្ញ ឬដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ថាបំពានសិទ្ធិចែងក្នុងសន្ធិសញ្ញា ដែលប្រទេសបារាំងក៏ជាភាគីដែរ។ បញ្ហាចោទជាចម្បងនោះ គឺនីតិវិធីស៊ើបអង្កេតបឋមដោយប៉ូលីស garde a vue ដែលប៉ូលីសមានអំណាចច្រើន អាចឃាត់ និងពន្យាពេលឃាត់ខ្លួន។ ដោយសារយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប នីតិវិធីឬច្បាប់របស់ប្រទេសបារាំង ត្រូវបានកែសម្រួល ពាក់ព័ន្ធផងដែរការបញ្ចេញព័ត៌មាន។

៥. ក្នុងអំឡុងពេលស៊ើបអង្កេតដោយនគរបាល÷ នគរបាល ត្រូវប្រាប់អំពីសិទ្ធិមានមេធាវី ប្រាប់អំពីមូលហេតុនៃការឃាត់ខ្លួន ហើយជនសង្ស័យអាចជួបមេធាវីបានភ្លាម តាំងពីដំណាក់កាលដំបូងក្រោយការឃាត់ខ្លួន។ ទោះបីជាយ៉ាងនេះក្តី មេធាវីមិនមានសិទ្ធិច្រើនក្នុងអំឡុងពេលជនសង្ស័យត្រូវបានសួរទេ។ ដូចគ្នានេះដែរ មេធាវីមិនទទួលបាននូវឯកសាររបស់នគរបាល ពាក់ព័ន្ធសំណុំរឿងកូនក្តីរបស់ខ្លួនជាដដែល។ មានការវិវឌ្ឍថ្មី តាមការទាមទាររបស់សហគមន៍អឺរ៉ុប ឲ្យប្រទេសបារាំងផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់ជនសង្ស័យ ក្នុងនោះ តម្រូវឲ្យនរគបាលប្រាប់ភ្លាមពីសិទ្ធិមានមេធាវី សិទ្ធិមិននិយាយ សិទ្ធិទទួលការបកប្រែ។

៦. ក្នុងអំឡុងស៊ើបអង្កេតដោយចៅក្រមស៊ើបសួរ ក្រោយពីបង្ហាញខ្លួនភ្លាម និងជាពិសេសក្រោយពីការដាក់ក្រោមការស៊ើបសួរ (judicial investigation) ជនត្រូវចោទ មានសិទ្ធិទទួលបានឯកសារតាមរយៈមេធាវី។ ចៅក្រមស៊ើបសួរ ត្រូវប្រាប់អំពីសិទ្ធិមានមេធាវី និងសិទ្ធិមិនឆ្លើយ និងប្រាប់អំពីមូលហេតុ

[1] The lack of access to the dossier and the scarce information disclosed on the nature of the offences prevents the lawyer from creating a more responsive defense strategy from the first meeting with his client. He must rely on the information provided by the suspect without any knowledge of the material gathered by the police.

នៃការដាក់ក្រោមការស៊ើបអង្កេត និងប្រភេទបទល្មើស។ ក្នុងអំឡុងសវនាការ÷ ជនជាប់ចោទ ក៏មានសិទ្ធិទទួលបានមេធាវី ចូលមើលសំណុំរឿងតាមរយៈមេធាវី ហើយចៅក្រមជំនុំជម្រះត្រូវប្រាប់អំពីបទចោទ..។

........................................................................................................

ដូចបានជម្រាបខាងលើ ប្រព័ន្ធស៊ីវិលឡដូចបារាំង ការបញ្ចេញព័ត៌មានដល់ភាគី មិនសូវមានភាពរឹងមាំដូចជាប្រព័ន្ធតទល់ (adversary system) នៃប្រព័ន្ធច្បាប់កុំមុនឡទេ។ ក្នុងប្រព័ន្ធនេះ រដ្ឋអាជ្ញា និងជនសង្ស័យការពារដោយមេធាវី មានសិទ្ធិធ្វើការស៊ើបអង្កេតដូចគ្នា។ រដ្ឋអាជ្ញា មានកាតព្វកិច្ចជាចម្បងក្នុងការបញ្ចេញនូវភស្តុតាងដល់ ជនជាប់ចោទ សូម្បីជាភស្តុតាងដោះបន្ទុកក្តី។ កាតព្វកិច្ចបញ្ចេញ (duty to disclose) នេះកើតមានអំឡុងពេលនីតិវិធីទាំងមូល។ ជនជាប់ចោទ ក៏មានកាតព្វកិច្ចបង្ហាញឲ្យដឹងអំពីមធ្យោបាយការពារខ្លួន ដូចជា ការលើកយកការដោះសារ (វិបល្លាសស្មារតី) ដល់រដ្ឋអាជ្ញា។ ការធ្វើយ៉ាងនេះ ដើម្បីឲ្យភាគីបដិបក្ខ ដឹង និងតបត ធានាបាននូវសមភាពរវាងភាគី (equality of arms)។ ការមិនបំពេញតាមកាតព្វកិច្ចបញ្ចេញព័ត៌មាន អាចនឹងនាំឲ្យមានការបដិសេធភស្តុតាង ឬទទួលការដាក់វិន័យតាមច្បាប់។